# នៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង នៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា

ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 10-Oct-2014, 10:39
CMS/CFO: Sann Rada

**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ៖ ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ត.ក

ភាគីដាក់ឯកសារ៖ លោក **ខៀវ សំផន**

ដាក់ជូន៖ ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង

ភាសាដើម៖ **បារាំង**

កាលបរិច្ឆេទឯកសារ៖ ថ្ងៃទី ១០ ខែ តុលា ឆ្នាំ ២០១៤

**ចំណាត់ថ្នាក់ឯកសារ**

ចំណាត់ថ្នាក់ឯកសារស្នើឡើងដោយភាគីដាក់ឯកសារ៖ **សាធារណៈ**

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង៖ សាធារណៈ/Public

ប្រភេទនៃចំណាត់ថ្នាក់៖

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់ណ្ដោះអាសន្ន៖

ឈ្មោះមន្ត្រីទទួលបន្ទុកផ្នែកសំណុំរឿង និងឯកសារ៖

ហត្ថលេខា៖

---

## បណ្ដឹងជំទាស់ថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

---

ដាក់ដោយ៖

**មេធាវីការពារក្ដីលោក ខៀវ សំផន**

មេធាវី គង់ សំអុន

មេធាវី Anta GUISSÉ

មេធាវី Arthur VERCKEN

ដាក់ជូន៖

**ក្រុមប្រឹក្សាជំនុំជម្រះពិសេស នៃអង្គជំនុំជម្រះសាលាដំបូង៖**

ចៅក្រម ធូ មណី

ចៅក្រម Rowan DOWNING

ចៅក្រម Chang-ho CHUNG

ចៅក្រម ប៉ែន ពេជ្រសាលី

**ជំនួយការ៖**
លោកស្រី សេង សុជាតា
កញ្ញា Marie CAPOTORTO
កញ្ញា Soumeya MEDJEBEUR
លោក Pierre TOUCHE
កញ្ញា អ៊ុំច ស្រីផាត់
កញ្ញា Cécile ROUBEIX
លោក Clément BOSSIS

ចៅក្រម ហ្វូត វុទ្ធី

**អង្គជំនុំជម្រះសាលាដំបូង**

**សហព្រះរាជអាជ្ញា**

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណីទាំងអស់**

**មេធាវីការពារក្តីលោក នួន ជា**

# តារាងមុខនៃអង្គជំនុំជម្រះសាលាដំបូង

## ប្រវត្តិនីតិវិធី

១. នៅថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ អង្គជំនុំជម្រះសាលាដំបូង ("អង្គជំនុំជម្រះ") បានប្រកាសសាលក្រមលើសំណុំរឿង ០០២/០១ និងបានប្រកាសថា លោក ខៀវ សំផន និង លោក នួន ជា ជាប់ពិរុទ្ធពីបទឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ដោយត្រូវផ្តន្ទាទោសដាក់ពន្ធនាគារអស់មួយជីវិត[1] ។ នៅថ្ងៃនោះដែរ ភាគីទាំងអស់បានទទួលសេចក្តីជូនដំណឹងអំពីសំណៅជាលាយល័ក្ខណ៍អក្សរនៃសាលក្រម ("សាលក្រម")[2]។

២. នៅថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីលោក ខៀវ សំផន ("មេធាវីការពារក្តី") បានដាក់"*សំណើរបស់ លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ*' ("សំណើសុំ")[3]។ ក្នុងសំណើចម្បងរបស់ខ្លួន មេធាវីការពារក្តីបានស្នើសុំឲ្យផ្អាកសវនាការ ដោយត្រូវរង់ចាំសាលដីកាស្ថាពររបស់អង្គជំនុំជម្រះតុលាការកំពូល ("តុលាការកំពូល") ហើយមេធាវីការពារក្តីបានបញ្ជាក់នៅក្នុងសំណើបន្ទាប់បន្សំរបស់ខ្លួនថា៖

> "*ទោះជាយ៉ាងណាក៏ដោយ បើអង្គជំនុំជម្រះគ្រោងបដិសេធសំណើផ្អាកសវនាការដែលជាសំណើចម្បងនេះ ជាបន្ទាប់បន្សំ មេធាវីការពារនឹងដាក់បណ្តឹងជំទាស់ដិតចិត្តលើចៅក្រមរបស់អង្គជំនុំជម្រះទាំងអស់ (ដោយរួមបញ្ចូលទាំងចៅក្រមបម្រុង លោកស្រី FENZ ផងដែរ ពីព្រោះគាត់បានចូលរួមជំនុំជម្រះជាច្រើនដងដែរ នៅក្នុងសវនាការសំណុំរឿង ០០២/០១ ហើយបានចូលរួមចេញសេចក្តីសម្រេចមួយចំនួនដែរ) ដើម្បីឲ្យសវនាការនៃសំណុំរឿង*

---

[1] ប្រតិចារឹក ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E1/241.1**។

[2] សាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E313** ("សាលក្រម")។

[3] សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E314/1**។

បណ្តឹងជំទាស់ដិតចិត្តសាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

*០០២/០២ ដំណើរការទៅមុខ ប្រសិនបើត្រូវចាប់ផ្ដើមភ្លាម ក្រោមការដឹកនាំរបស់ក្រុមប្រឹក្សាជំនុំជម្រះថ្មី ដែលមិនចេញសេចក្ដីសម្រេចលើទំនួលខុសត្រូវព្រហ្មទណ្ឌរបស់លោក ខៀវ សំផន ចំពោះអង្គហេតុដែលសន្មតថាជាកម្មវត្ថុនៃសំណុំរឿង ០០២/០២ និងសំណុំរឿងបន្តបន្ទាប់*។

៣. នៅថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ការិយាល័យរដ្ឋបាលរបស់ អ.វ.ត.ក បានចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះពិសេសមួយ ("ក្រុមប្រឹក្សាជំនុំជម្រះពិសេស") ដើម្បីសម្រេចលើបណ្ដឹងជំទាស់របស់មេធាវីការពារក្ដី។

៤. តាមរយៈសេចក្ដីសម្រេចចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ("សេចក្ដីសម្រេច") អង្គជំនុំជម្រះបានបដិសេធសំណើរបស់លោក ខៀវ សំផន សុំពន្យារការចាប់ផ្ដើមសំណុំរឿង ០០២/០២ ដោយត្រូវរង់ចាំសាលដីកាស្ថាពររបស់តុលាការកំពូល[4]។ នៅថ្ងៃជាមួយគ្នានោះដែរ អង្គជំនុំជម្រះបានចេញ "*ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២*"[5] ដោយបានកំណត់ផ្នែកទីមួយនៃសវនាការពិភាក្សាដេញដោល ចាប់ពីថ្ងៃទី ១៧ ខែ តុលា ដល់ថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០១៤[6]។

៥. នៅថ្ងៃទី ២៩ ខែ កញ្ញា ក្រុមមេធាវីការពារក្ដីលោក នួន ជា ("មេធាវីការពារក្ដីលោក នួន ជា") បានដាក់បណ្ដឹងជំទាស់ប្រឆាំងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្ដារា ("បណ្ដឹងជំទាស់")[7]។

---

[4] សេចក្ដីសម្រេចលើសំណើរបស់ ខៀវ សំផន សុំពន្យារការចាប់ផ្ដើមសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E314/5** ("សេចក្ដីសម្រេច")។

[5] ដីកាកំណត់កាលបរិច្ឆេទសម្រាប់សវនាការលើអង្គសេចក្ដីក្នុងសំណុំរឿង ០០២/០២ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E316** ("ដីកាកំណត់កាលបរិច្ឆេទ")។

[6] ដីកាកំណត់កាលបរិច្ឆេទ ឯកសារ **E316** ទំព័រ ៥ និងឧបសម្ព័ន្ធ **E316.1**។

[7] បណ្ដឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្ដារា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E314/6**។

បណ្ដឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

៦. នៅថ្ងៃនោះដែរ មេធាវីការពារក្ដីទាំងពីរក្រុម បានដាក់សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខ ដែលក្នុងនោះមានបញ្ជាក់ពីមូលហេតុមួយចំនួនធំនៃបណ្ដឹង ហើយជាពិសេសទៅទៀតនោះ គឺកំហុសជាច្រើនពាក់ព័ន្ធនឹងការរំលោភគោលការណ៍នៃការជំនុំជម្រះក្ដីដោយយុត្តិធម៌[8]។

៧. នៅថ្ងៃទី ០៣ ខែ តុលា ឆ្នាំ ២០១៤ មេធាវីការពារក្ដីបានដាក់សំណើមួយ សុំឱ្យអង្គជំនុំជម្រះពិនិត្យឡើងវិញពីដីកាកំណត់កាលបរិច្ឆេទ ដើម្បីអនុញ្ញាតឱ្យលោក ខៀវ សំផន អាចអនុវត្តសិទ្ធិការពារខ្លួនឱ្យបានពេញលេញ ដោយគាត់ត្រូវចំណាយពេលទៅលើការសរសេរសារណាបណ្ដឹងសាទុក្ខក្នុងរយៈពេលមួយដែលត្រូវបានកំណត់ជូនគាត់។ នៅក្នុងសំណើរបស់ខ្លួន មេធាវីការពារក្ដីបានបង្ហាញផងដែរ ពីភាពចាំបាច់ក្នុងការរង់ចាំសេចក្ដីសម្រេចលើបណ្ដឹងជំទាស់របស់មេធាវីការពារក្ដីទាំងពីរក្រុម ដើម្បីភាពច្បាស់លាស់ និងប្រសិទ្ធិភាពនៃដំណើរការនីតិវិធី។

៨. តាមរយៈសំណើសុំនេះ មេធាវីការពារក្ដីមានបំណងលើកឡើងសាជាថ្មីនៅចំពោះមុខក្រុមប្រឹក្សាជំនុំជម្រះពិសេស នូវបណ្ដឹងជំទាស់របស់ខ្លួន ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ និងជាពិសេសជាងនេះទៅទៀតនោះ មេធាវីការពារក្ដីស្នើសុំឱ្យផ្អាកសវនាការលើសំណុំរឿង ០០២/០២។

**ពាក់ព័ន្ធនឹងការលើកឡើងសាជាថ្មីនូវបណ្ដឹងជំទាស់ប្រឆាំងនឹងចៅក្រមដែលបានចូលរួមក្នុងការសម្រេចលើសាលក្រម និងលោកស្រីចៅក្រម Claudia FENZ**

៩. មេធាវីការពារក្ដីយល់ស្របតាមយុត្តិសាស្ត្រ និងទឡ្ហីករណ៍របស់មេធាវីការពារក្ដីលោក នួន ជា ពាក់ព័ន្ធនឹងច្បាប់ជាធរមានក្នុងការធ្វើបណ្ដឹងជំទាស់ ដូចដែលត្រូវបានលើកឡើងនៅក្នុងសំណើសុំរបស់មេធាវីក្រុមនេះ[9]។ ម្យ៉ាងវិញទៀត មេធាវីការពារក្ដី មានជំហរដូចគ្នាទាក់ទិននឹងភាពលំអៀងរបស់អង្គជំនុំជម្រះ ដូចដែលត្រូវបានលើកឡើងនៅក្នុងសៀវភៅរបស់អតីតសហចៅក្រមស៊ើប

---

[8] សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខរបស់មេធាវីការពារក្ដីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E313/2/1**, សេចក្ដីជូនដំណឹងអំពីបណ្ដឹងសាទុក្ខប្រឆាំងនឹងសាលក្រមក្នុងសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E313/1/1**។

[9] បណ្ដឹងជំទាស់របស់ នួន ជា ប្រឆាំងនឹងចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE និងចៅក្រម យូរ ឧត្ដារា ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E314/6** កថាខណ្ឌ ១៥-៣៤។

បណ្ដឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

អង្កេត លោក Marcel LEMONDE នៅក្នុងសេចក្តីថ្លែងជាសាធារណៈរបស់លោកស្រីចៅក្រម Sylvia CARTWRIGHT និងនៅក្នុងសេចក្តីសម្រេចក្រោយមកទៀតរបស់អង្គជំនុំជម្រះលើបញ្ហាសាក្សី។ ធាតុផ្សំទាំងអស់នេះ គឺជាមូលហេតុបន្ថែមនាំឲ្យមានការសង្ស័យលើភាពមិនលំអៀងរបស់ចៅក្រមនៃអង្គជំនុំជម្រះ។ ម្យ៉ាងវិញទៀត ធាតុផ្សំទាំងអស់នេះ ស្ថិតក្នុងចំណោមមូលហេតុទាំងឡាយនៃបណ្តឹងសាទុក្ខរបស់ លោក ខៀវ សំផន[10]។

១០. ពាក់ព័ន្ធនឹងមូលហេតុដែលថា វាពិតជាមិនអាចទៅរួចឡើយដែលចៅក្រមដែលបានចូលរួមសម្រេចនៅក្នុងសំណុំរឿង ០០២/០១ អាចកាត់សេចក្តីជនជាប់ចោទនៅក្នុងសំណុំរឿង ០០២/០២ ដោយយុត្តិធម៌ មេធាវីការពារក្តីសុំឲ្យក្រុមប្រឹក្សាជំនុំជម្រះពិសេសយោងទៅលើទឡ្ហីករណ៍របស់ខ្លួន ដូចដែលបានបង្ហាញនៅក្នុងសំណើ E314/1។ មេធាវីការពារក្តីយោងផងដែរទៅលើសេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់ខ្លួន ចុះថ្ងៃទី ២៩ ខែ កញ្ញា[11] ដែលបានរៀបរាប់យ៉ាងលម្អិតពីសេចក្តីសន្និដ្ឋានរបស់សាលក្រម ដែលច្បាស់ថានឹងមានឥទ្ធិពលទៅលើសំណុំរឿង ០០២/០២ ដោយមូលហេតុថា សេចក្តីសន្និដ្ឋានទាំងអស់នោះ គឺជា"បុរេវិនិច្ឆ័យ"លើពិរុទ្ធភាពរបស់រូបលោក ខៀវ សំផន ពាក់ព័ន្ធនឹងអង្គហេតុមួយចំនួនក្នុងសំណុំរឿង០០២/០២ ដែលមិនទាន់ត្រូវបានពិភាក្សាដេញដោល។

១១. ខ្លឹមសារលើកឡើងដោយមេធាវីការពារក្តីលោក នួន ជា នៅក្នុងសំណើរបស់ខ្លួនពាក់ព័ន្ធនឹងសេចក្តីសន្និដ្ឋានរបស់អង្គជំនុំជម្រះនៅក្នុងសាលក្រម ដោយហេតុថាសេចក្តីសន្និដ្ឋានទាំងអស់នោះបង្ហាញឲ្យឃើញពីភាពលំអៀង[12] គឺស្របគ្នាទៅនឹងទឡ្ហីករណ៍លើកឡើងដោយមេធាវីការពារក្តី លោក ខៀវ សំផន នៅក្នុងសំណើសុំរបស់ខ្លួន[13]។

---

[10] សេចក្តីជូនដំណឹងអំពីបណ្តឹងសាទុក្ខរបស់មេធាវីការពារក្តីលោក ខៀវ សំផន ប្រឆាំងនឹងសាលក្រមលើសំណុំរឿង ០០២/០១ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០១៤ ឯកសារ **E313/2/1** កថាខណ្ឌ ១១ និងកថាខណ្ឌ ៤០ ជើងទំព័រ ៤៣។

[11] ដូចខាងលើ។

[12] បណ្តឹងជំទាស់ជាមួយ... 

[13] សំណើរបស់លោក ខៀវ សំផន សុំឲ្យពិនិត្យឡើងវិញពីភាពចាំបាច់ក្នុងការរង់ចាំសាលក្រមក្នុងសំណុំរឿង ០០២/០១ ចូលជាស្ថាពរ មុននឹងចាប់ផ្តើមការជំនុំជម្រះសំណុំរឿង ០០២/០២ និងសុំឲ្យពិនិត្យឡើងវិញពីការចាត់តាំងក្រុមប្រឹក្សាជំនុំជម្រះថ្មីមួយ ចុះថ្ងៃទី ២៥ ខែ សីហា ឆ្នាំ ២០១៤ ឯកសារ **E314/1** កថាខណ្ឌ ២៣-៣៥, ៤២។

បណ្តឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

១២. នៅទីបញ្ចប់ មេធាវីការពារក្តីសូមរំឭកថា សំណើសុំរបស់ខ្លួនពាក់ព័ន្ធផងដែរនឹងលោកស្រីចៅក្រម FENZ ព្រោះថា លោកស្រីបានជំនួសលោកស្រីចៅក្រម CARTWRIGHT ឬ លោកចៅក្រម LAVERGNE ជាច្រើនដងក្នុងអំឡុងពេលសវនាការពិភាក្សាដេញដោលក្នុងសំណុំរឿង ០០២/០១ ហើយដូច្នេះ លោកស្រីបានចូលរួមក្នុងការធ្វើសេចក្តីសម្រេចជាច្រើន[14]។

**ពាក់ព័ន្ធនឹងសំណើសុំឱ្យមានសវនាការសាធារណៈ និងសំណើសុំផ្អាកសវនាការសំណុំរឿង ០០២/០២ ដោយត្រូវរង់ចាំសេចក្តីសម្រេចដែលនឹងត្រូវចេញ**

១៣. ការជំនុំជម្រះលើរូប លោក ខៀវ សំផន គឺជាការជំនុំជម្រះសាធារណៈ។ យោងទៅលើសារៈសំខាន់នៃបញ្ហាទាំងឡាយដែលត្រូវបានលើកឡើងដោយបណ្តឹងជំទាស់ ជាពិសេសតាមគោលការណ៍នៃការជំនុំជម្រះក្តីដោយយុត្តិធម៌ មេធាវីការពារក្តីស្នើសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះពិសេស ស្តាប់ទឡ្ហីករណ៍របស់ភាគីទាំងអស់ក្នុងអំឡុងពេលសវនាការសាធារណៈ។ សំណើនេះមានគោលបំណងឱ្យប្រជាជនខ្មែរបានយល់ និងបានតាមដានទស្សនាការពិភាក្សាដេញដោល។

១៤. នៅក្នុងសារណារបស់ខ្លួនកាលពីខែ សីហា ឆ្នាំ ២០១៤ មេធាវីការពារក្តីបានស្នើរួចមកហើយ សុំឱ្យផ្អាកសវនាការលើសំណុំរឿង ០០២/០២ ដោយត្រូវរង់ចាំសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាជំនុំជម្រះពិសេស។ សំណើនេះផ្តើមចេញមកពីភាពសមហេតុផលមួយដែលខុសគ្នាពីភាពសមហេតុផលដែលកំពុងរង់ចាំការសម្រេចនាពេលបច្ចុប្បន្នពីអង្គជំនុំជម្រះសាលាដំបូង ក្នុងការសុំឱ្យផ្អាកសវនាការលើសំណុំរឿង ០០២/០២ ដើម្បីផ្តល់ពេលវេលាឱ្យមេធាវីការពារក្តីរៀបចំបណ្តឹងសាទុក្ខក្នុងសំណុំរឿង ០០២/០១។ សំណើនេះកើតចេញមកពីការណ៍ដែលថា ខណៈដែលជនជាប់ចោទទាំងពីររូបបានលើកឡើងពីការព្រួយបារម្ភយ៉ាងខ្លាំង ទាក់ទិននឹងលទ្ធភាពក្នុងការទទួលបានការជំនុំ

[14] លោកស្រីចៅក្រម FENZ បានជំនួស លោកស្រីចៅក្រម CARTWRIGHT ឬ លោកចៅក្រម LAVERGNE ពីថ្ងៃទី ១៦ ដល់ថ្ងៃទី ២៣ ខែ មករា ឆ្នាំ ២០១២ (ឯកសារ **E1/27.1** ដល់ឯកសារ **E1/30.1**) ពីថ្ងៃទី ១៣ ដល់ថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ២០១២ (ឯកសារ **E1/42.1** ដល់ឯកសារ **E1/45.1**) ថ្ងៃទី ០៥ ខែ មេសា ឆ្នាំ ២០១២ (ឯកសារ **E1/60.1**) ថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០១២ (ឯកសារ **E1/116.1**) ថ្ងៃទី ០៣ ខែ កញ្ញា ឆ្នាំ ២០១២ (ឯកសារ **E1/120.1**) ថ្ងៃទី ១៧ ខែ ធ្នូ ឆ្នាំ ២០១២ (ឯកសារ **E1/155.1**) ពីថ្ងៃទី ១៨ ខែ កុម្ភៈ ដល់ថ្ងៃទី ០៤ ខែ មីនា ឆ្នាំ ២០១៣ (ឯកសារ **E171.1.1** ដល់ឯកសារ **E1/174.1**)។
បណ្តឹងជំទាស់សាជាថ្មី ប្រឆាំងនឹងសមាសភាពចៅក្រមបច្ចុប្បន្ននៃអង្គជំនុំជម្រះសាលាដំបូង ដែលត្រូវសម្រេចលើសំណុំរឿង ០០២/០២

ជម្រះដោយយុត្តិធម៌ វាដូចជាជាពុំឆ្លើយតបទៅនឹងដំណើរការគ្រប់គ្រងតុលាការឱ្យបានត្រឹមត្រូវល្អ ដោយត្រូវចាប់ផ្តើមកិច្ចពិភាក្សាដេញដោលឡើងវិញ មុនពេលដែលសំណើសុំរបស់ពួកគាត់មិនទាន់ត្រូវបានសម្រេចនោះ។

## ផ្អែកតាមសំអាងហេតុខាងលើនេះ

## មេធាវីការពារក្តី លោក ខៀវ សំផន ស្នើក្រុមប្រឹក្សាជំនុំជម្រះពិសេស មេត្តា៖

- **ដក**ចៅក្រម និល ណុន ចៅក្រម យ៉ា សុខន ចៅក្រម Jean-Marc LAVERGNE ចៅក្រម យូរ ឧត្តរា និងចៅក្រម Claudia FENZ ចេញពីរាល់ដំណើរការនីតិវិធីពាក់ព័ន្ធនឹងលោក ខៀវ សំផន ដោយអនុលោមតាមវិធាន ៣៤ នៃវិធានផ្ទៃក្នុង និងស្នើសុំឱ្យជំនួសចៅក្រមទាំងអស់ខាងលើ ដោយក្រុមប្រឹក្សាចៅក្រមថ្មីមួយ ដែលត្រូវទទួលភារកិច្ចជំនុំជម្រះសំណុំរឿង ០០២/០២ ដោយឥតលំអៀង។
- **ផ្អាក**ដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ដោយត្រូវរង់ចាំការតែងតាំងចៅក្រមបម្រុង។

**ក្នុងករណីណាក្តី៖**

- **កំណត់ធ្វើ**សវនាការសាធារណៈ ដើម្បីធ្វើការដេញដោលពាក់ព័ន្ធនឹងបណ្តឹងជំទាស់នេះ។
- **ផ្អាក**ដំណើរការនីតិវិធីសំណុំរឿង ០០២/០២ ដរាបណាបណ្តឹងជំទាស់នេះមិនទាន់ត្រូវបានសម្រេចទាំងស្រុង។

| | | | |
|---|---|---|---|
| | មេធាវី គង់ សំអុន | រាជធានីភ្នំពេញ | |
| | មេធាវី Anta GUISSÉ | ទីក្រុងប៉ារីស | |
| | មេធាវី Arthur VERCKEN | ទីក្រុងប៉ារីស | |